CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ២៩ ខែមិថុនាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចនឹងបិទឆ្នេរសមុទ្រនៅចុងសប្តាហ៍នៃទិវាឯករាជ្យជាតិ

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ទីក្រុងឡុងប៊ិចបានប្រកាសនៅថ្ងៃនេះថាស្របនឹងខោនធី Los Angeles ឆ្នេរសមុទ្រនៅឡុងប៊ិចនឹងត្រូវបិទជាសាធារណៈនៅចុងសប្តាហ៍នៃទិវាឯករាជ្យជាតិនេះដោយនឹងចាប់ផ្តើមពីថ្ងៃសុក្រទី 3 ខែកក្កដា (នៅម៉ោង 12:01 អធ្រាត្រ) ដល់ម៉ោង 5 ព្រឹកនៅថ្ងៃច័ន្ទទី 6 ខែកក្កដាក្នុងកិច្ចខិតខំយ៉ាងសកម្មដើម្បីទប់ស្កាត់ការរាលដាលនៃ COVID-19។ ការបិទនេះក៏រួមបញ្ចូលទាំងផៃ ចំណតរថយន្តនៅឆ្នេរសមុទ្រ (លើកលែងតែអ្នកដែលមានប័ណ្ណអនុញ្ញាត) ផ្លូវចូលទៅដល់ឆ្នេរ បន្ទប់ទឹក ផ្លូវសម្រាប់ជិះកង់និងផ្លូវថ្មើរជើង។

ដោយសារតែការកើនឡើងយ៉ាងខ្លាំងនាពេលថ្មីៗនេះនៃករណី COVID-19 និងអត្រាវិជ្ជមាននៅទាំងឡុងប៊ិចនិងខោនធីហើយដោយសារតែឆ្នេរសមុទ្រជាធម្មតាទាក់ទាញការជួបជុំធំៗឆ្នេរទាំងអស់នៅឡុងប៊ិចនឹងបិទជាបណ្តោះអាសន្នទាំងសម្រាប់ការប្រើប្រាស់អកម្មនិងសកម្ម។ ឆ្នេរសមុទ្រនឹងបើកដំណើរការវិញនៅម៉ោង 5:01 ព្រឹកនៅថ្ងៃច័ន្ទទី 6 ខែកក្កដា។

ទីក្រុងឡុងប៊ិចបានលើកទឹកចិត្តឱ្យប្រជាជនអបអរសាទរនៅផ្ទះដោយសុវត្ថិភាពនៅទិវាឯករាជ្យជាតិឆ្នាំមនេះនិងណែនាំវិធីផ្សេងៗដើម្បីអបអរជាមួយនឹងសមាជិកគ្រួសាររបស់ពួកគាត់ដូចជាការអាង់សាច់នៅផ្ទះដោយគ្មានការបាញ់កាំជ្រួចឬការមើលខ្សែភាពយន្តជាលក្ខណៈគ្រួសារ។ ព្រឹត្តិការណ៍ដូចជាការបង្ហាញកាំជ្រួចពិធីជប់លៀងតាមសង្កាត់និងការប្រជុំធំ ៗដទៃទៀតមិនត្រូវបានអនុញ្ញាតទេយោងទៅតាមបទបញ្ជាសុខភាពរបស់រដ្ឋកាលីហ្វ័រញ៉ា។ ប្រសិនបើលោកអ្នកនឹងអបអរសាទរដោយទៅខាងក្រៅ

មន្ត្រីសុខាភិបាលក្រុងបានក្រើនរំលឹកដល់ប្រជាជនអោយរក្សាចម្ងាយយ៉ាងតិច 6 ហ្វីតពីបុគ្គលដទៃដែលមិនមែននៅក្នុងគ្រួសារតែមួយ សូមពាក់របាំងមុខដែលគ្របទៅលើមាត់និងច្រមុះនៅគ្រប់ទីកន្លែងសាធារណៈនិងឯកជនដែលលោកអ្នកអាចនឹងទំនាក់ទំនងជាមួយនឹងសមាជិកនៃគ្រួសារផ្សេងទៀត សូមលាងដៃឱ្យបានញឹកញាប់និងបំបាត់មេរោគលើផ្ទៃដែលតែងតែប៉ះជាញឹកញាប់។

សកម្មភាពនេះត្រូវបានបង្កើតឡើងដោយមន្ត្រីសុខាភិបាលទីក្រុងគឺវេជ្ជបណ្ឌិត Anissa Davis និងយោងទៅតាមអំណាចបន្ទាន់ (Emergency Powers) ដែលផ្ដល់ទៅឱ្យអ្នកគ្រប់គ្រងក្រុងតាមរយៈការប្រកាសអាសន្នក្នុងតំបន់ (Proclamation of Local Emergency)។ សកម្មភាពនេះនឹងមានប្រសិទ្ធភាពនៅថ្ងៃទី 3 ខែកក្កដាឆ្នាំ 2020 នៅម៉ោង 12:01 ព្រឹកហើយនឹងបន្តរហូតដល់ថ្ងៃច័ន្ទទី 6 ខែកក្កដាឆ្នាំ 2020 នៅម៉ោង 5 ព្រឹក។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័ហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

###